# ផែនការគ្រប់គ្រងការប្រឈម/ប៉ះពាល់ជំងឺ COVID-19: ពិធីសារសំរាប់សាលា K-12: ឧបសម្ព័ន្ធ X2

សំគាល់: ឯកសារពិធីសារនេះអាចត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលមាននូវព័ត៌មាន និងធនធានថ្មីៗ។ ពិនិត្យមើលគេហទំព័រ COVID-19 របស់នាយកដ្ឋានសុខាភិបាល និងសេវាមនុស្សទីក្រុងឡុងប៊ីឆ: ចូលទៅកាន់ www.longbeach.gov/covid19 ដើម្បីព័ត៌មានថ្មីៗ ចំពោះឯកសារនេះ។

ការឆ្លើយតបសុខភាពសាធារណៈជាគោលដៅ ដើម្បីគ្រប់គ្រងជំងឺ COVID-19 នៅកម្រិតសហគមន៍ អាចជួយបង្កើនឥទ្ធិពល ឬផលប៉ះពាល់ នៃការឆ្លើយតបទៅនឹងជំងឺ COVID-19 ឡុងប៊ីឆ។

សាលាបឋមសិក្សា និងមធ្យមសិក្សាដែលកំពុងបម្រើសិស្សចាប់ពីថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី ១២ (សាលា K-12) គឺជាដៃគូសហគមន៍ដែលអាចជឿទុកចិត្តបាន ដែលអាចជួយនាយកដ្ឋានសុខាភិបាលឡុងប៊ីឆ ធ្វើអោយទាន់ពេលវេលា និងផលប៉ះពាល់នៃការឆ្លើយតបសុខភាពសាធារណៈ តាមរយៈការផ្តួចផ្តើមផែនការគ្រប់គ្រងការប្រឈមជំងឺ COVID-19 (EMP) នៅពេលមានការផ្តល់ដំណឹងអំពីករណីជំងឺ COVID-19 និងបណ្តុំ/ចង្កោមនៃជំងឺនៅសាលារៀន។ EMP សាលារៀន អាចត្រូវបានអនុវត្តមុនពេលដែលជំងឺ COVID-19 ត្រូវបានរាយការណ៍ទៅកាន់នាយកដ្ឋានសុខាភិបាល, ដោយហេតុនេះ បង្កើននូវសមត្ថភាពគ្រប់គ្រងការរីករាលដាលនៃជំងឺ COVID-19 និងបង្ការការផ្ទុះឡើងនៅសាលារៀន ពីការកើតឡើងបាន។

ជំហ៊ានសំរាប់ការគ្រប់គ្រងការប្រឈម/ប៉ះពាល់ នៃជំងឺ COVID-19 ករណីទី ១, ទី ២, និងទី ៣ ឬច្រើនជាងនេះ នៅសាលា K-12 ត្រូវបានពិពណ៌នាដូចខាងក្រោម និងសង្ខេបនៅក្នុងតារាង A។ ដោយសារសាលារៀនថ្នាក់ K-12 និងមានភាពខុសគ្នា នៅក្នុងកម្រិតនៃធនធានសម្រាប់ការគ្រប់គ្រងការប្រឈមជំងឺ COVID-19, ជំហ៊ាននានាដែលត្រូវការ គឺជាធាតុអប្បបរមា ដែលគួរតែត្រូវបានរាប់បញ្ចូលក្នុង EMP សាលា។ ជំហ៊ាននានាដែលបានណែនាំ រួមមានធាតុសម្រាប់ការគ្រប់គ្រងតាមមូលដ្ឋាននៃការប្រឈម ដែលមានធនធានសាលារៀននានា។

LONGBEACH HEALTH & HUMAN SERVICES

## ការធ្វើផែនការគ្រប់គ្រងការប្រឈម/ប៉ះពាល់ មុនពេលមានជំងឺ COVID-19 មួយករណី នៅសាលារៀន

- ☐ **ចាំបាច់ធ្វើ៖** ក្រុមការងារអនុលោមតាមជំងឺ COVID-19 ដែលបានត្រូវចាត់តាំងរបស់សាលារៀន ដែលទទួលខុសត្រូវក្នុងការបង្កើត និងអនុវត្តនូវរាល់ពិធីសារសុវត្ថិភាពជំងឺ COVID-19 និងធានាថាបុគ្គលិក និងសិស្ស ទទួលបានការអប់រំ អំពីជំងឺ COVID-19។ មន្ត្រីអនុលោមតាមច្បាប់ជំងឺ COVID-19 ដែលបានត្រូវចាត់តាំង ជាអ្នកនាំពាក្យទៅកាន់នាយកដ្ឋានសុខាភិបាល ក្នុងករណីមានបណ្តឹ/ចង្អោម ឬការផ្ទុះឡើងនៃជំងឺ COVID-19 នៅឯសេតជីងសាលារៀន។
- ☐ **ចាំបាច់ធ្វើ៖** ផែនការសម្រាប់សិស្ស និងនិយោជិកទាំងអស់ ដែលត្រូវបានគេសង្ស័យថាមានជំងឺ COVID-19 ឬត្រូវបានដាក់អោយធ្វើចត្តាឡីស័ក ដោយសារតែការប្រឈម/ប៉ះពាល់នឹងករណី (ច្រើន) នៅសាលារៀនដើម្បីទទួលបានការធ្វើតេស្ត ឬត្រូវបានធ្វើតេស្ត សម្រាប់ជំងឺ COVID-19។

## ការគ្រប់គ្រងការប្រឈម/ប៉ះពាល់សំរាប់ជំងឺ COVID-19 មួយករណី នៅសាលារៀន

- ☐ **ចាំបាច់ធ្វើ៖** ប្រសិនបើសាលារៀនត្រូវបានជូនដំណឹងអំពីករណីដែលបានបញ្ជាក់ចំនួន ១ ករណី (សិស្ស ឬនិយោជិក) ក្រុមការងារអនុលោមតាមរបស់សាលារៀន ស្នើសុំអោយករណីនោះ អនុវត្តតាម សេចក្តីណែនាំអំពីការដាក់ខ្លួនឯងអោយនៅឯកោនៅផ្ទះ សំរាប់ជំងឺ COVID-19។
- ☐ **ចាំបាច់ធ្វើ៖** ក្រុមការងារអនុលោមតាមសាលារៀន ធ្វើការជាមួយករណី ដើម្បីបង្កើតបញ្ជីឈ្មោះសិស្ស និងនិយោជិក ដែលមានការប្រឈម/ប៉ះពាល់នឹងករណីនេះ ក្នុងកំឡុងពេលឆ្លងរោគ ដោយប្រើ សន្លឹកកិច្ចការជំងឺ COVID-19។ មន្ត្រីអនុតាមតាមសាលារៀន ផ្តល់ជូនដល់នាយកដ្ឋានសុខាភិបាលឡុងប៊ីច នូវសន្លឹកកិច្ចការដែលបានបំពេញរួច ក្នុងរយៈពេល ១ ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានជូនដំណឹងអំពីករណីដែលបានបញ្ជាក់។
    - ករណីមួយ ត្រូវបានគេចាត់ទុកថាឆ្លងពី ២ ថ្ងៃ មុនពេលរោគសញ្ញានានារបស់ពួកគេ លេចចេញមកជាលើកដំបូង រហូតដល់ពេលដែលពួកគេមិនត្រូវបានដាក់អោយនៅដាច់ឆ្ងាយឯកោ (មានន័យថា, មិនគ្រុនក្តៅ យ៉ាងហោចណាស់រយៈពេល ២៤ ម៉ោង, ដោយមិនប្រើថ្នាំដែលបន្ថយគ្រុន

ក្តៅ **និង** ប្រព័ន្ធនានាបានប្រសើរឡើង **និង** យ៉ាងហោចណាស់ ១០ ថ្ងៃ បានកន្លងផុតទៅ ចាប់តាំងពីរោគសញ្ញានានា បានលេចចេញឡើងដំបូង) ។ មនុស្សម្នាក់ដែលតេស្តជំងឺ COVID-19 ឃើញមានវិជ្ជមាន ប៉ុន្តែមិនមានរោគសញ្ញាអ្វីនោះទេ ត្រូវបានគេចាត់ទុកថាឆ្លងពី ២ ថ្ងៃ មុនពេលការធ្វើតេស្តរបស់ពួកគេ ត្រូវបានធ្វើឡើង រហូតដល់ ១០ ថ្ងៃ ក្រោយពីការធ្វើតេស្តរបស់ពួកគេ។

- មនុស្សម្នាក់ ត្រូវបានគេចាត់ទុកថាបានប្រឈម ប្រសិនបើពួកគេ ជាមនុស្សម្នាក់ ដូចខាងក្រោម:
    - បុគ្គលដែលបានស្ថិតក្នុងចម្ងាយ ៦ ហ្វីត នៃអ្នកដែលបានឆ្លងជំងឺនេះ អស់រយៈពេលច្រើនជាង ១៥ នាទី, បើទោះបីជាមានការពាក់គម្របមុខ មិនមែនជាគម្របមុខវេជ្ជសាស្ត្រក៏ដោយ;
    - បុគ្គលដែលមានទំនាក់ទំនងដោយមិនបានការពារ ជាមួយនឹងវត្ថុរាវរាងកាយ និង/ឬទឹករំអិលរបស់មនុស្សម្នាក់ ដែលមានការបញ្ជាក់ថា ឬមានការសង្ស័យថា មានជំងឺ COVID-19 (ឧទាហរណ៍ ត្រូវបានគេក្អកដាក់ ឬកណ្តាស់ដាក់, ចែករំលែកប្រដាប់ប្រដាប្រើប្រាស់ ឬទឹកមាត់, ឬផ្តល់នូវការថែទាំ ដោយមិនប្រើឧបករណ៍ការពារសមស្រប)។

- **ចាំបាច់ធ្វើ៖** សិស្ស និងនិយោជិក ដែលត្រូវបានគេកំណត់អត្តសញ្ញាណថាមានការប្រឈម/ប៉ះពាល់ទៅនឹងករណី ត្រូវបានជូនដំណឹងដោយក្រុមការងារអនុលោមរបស់សាលារៀន តាមរយៈលិខិតមួយច្បាប់ ឬយុទ្ធសាស្ត្រទំនាក់ទំនងផ្សេងទៀត (ឧទាហរណ៍ តាមទូរស័ព្ទ, អត្ថបទសារ, ទូរស័ព្ទ ឬសារជាក្រុម)។ គំរូលិខិតជូនដំណឹង អំពីការប្រឈម/ប៉ះពាល់នៅឬក្នុងសាលារៀន មាននៅឯ: គំរូលិខិតជូនដំណឹងសំរាប់គ្រឹះស្ថានអប់រំ អំពីជំងឺ COVID-19។ ការជូនដំណឹងគួរតែមានរួមបញ្ចូលនូវធាតុនានា ដូចខាងក្រោម:
    - ផ្តល់អនុសាសន៍ ដល់និស្សិត និងនិយោជិក ដែលមានការប្រឈម/ប៉ះពាល់នឹងករណីនេះ ដើម្បីធ្វើតេស្តសំរាប់ជំងឺ COVID-19, ជាការល្អបំផុត ១០ ថ្ងៃ បន្ទាប់ពីរយៈពេលនៃការចត្តាឡីស័ករបស់ពួកគេ បានចាប់ផ្តើម, ទោះបីជាពួកគេមានរោគសញ្ញា ឬអត់ក៏ដោយ, ហើយប្រាប់សាលារៀននូវលទ្ធផលនៃការធ្វើតេស្ត ប្រសិនបើវិជ្ជមាន។ ប្រសិនបើមនុស្សនោះ ធ្វើតេស្តឃើញអវិជ្ជមាន ក្នុងកំឡុងពេលនៃការធ្វើចត្តាឡីស័ក, ពួកគេនៅតែត្រូវបន្តធ្វើចត្តាឡីស័ក ក្នុងរយៈពេល ១៤ ថ្ងៃនោះអោយបានទាំងស្រុង។ នេះនឹងកំណត់វិសាលភាពនៃការរីករាលដាលនៃជំងឺ នៅសាលារៀន និងបំរើជាមូលដ្ឋានសម្រាប់វិធានការណ៍ត្រួតពិនិត្យបន្តទៀត។

- ធនធានសម្រាប់ការធ្វើតេស្ត រួមបញ្ចូលនូវៈ សេវាកម្មសុខភាពនិយោជិក ឬសេវាកម្មសុខភាពវិជ្ជាជីវៈ, មជ្ឈមណ្ឌលសុខភាពសិស្ស, អ្នកផ្តល់សេវាថែទាំសុខភាពផ្ទាល់ខ្លួន, កន្លែងធ្វើតេស្តសហគមន៍។ ឯកត្តបុគ្គលដែលត្រូវការជំនួយ ក្នុងការស្វែងរកអ្នកផ្តល់សេវាវេជ្ជសាស្ត្រ អាចទូរស័ព្ទទៅកម្មវិធីផ្សព្វផ្សាយមេឌីខាល តាមលេខ ៥៦២.៥៧០.៧៩៧៩។
  - ណែនាំសិស្ស និងនិយោជិកអោយធ្វើចត្តាឡីស័ក រយៈពេល ១៤ ថ្ងៃ ចាប់តាំងពីការប្រឈមចុងក្រោយទៅនឹងករណី ខណៈពេលឆ្លង, ទោះបីជាពួកគេទទួលបានលទ្ធផលតេស្តអវិជ្ជមាន ក្នុងកំឡុងពេលនៃការធ្វើចត្តាឡីស័ក ក៏ដោយ។ មនុស្សម្នាក់ដែលធ្វើតេស្តឃើញអវិជ្ជមាន ក្នុងកំឡុងពេលភ្ញាស់/កំឡុងពេលមេរោគសំងំក្នុងខ្លួន (ពេលគឺ រយៈពេលរវាងការប្រឈម/ប៉ះពាល់ នឹងការចាប់ផ្តើមជំងឺ) អាចនឹងវិវត្តន៍ ទៅជាជំងឺជាបន្តបន្ទាប់, ដោយមាន ឬគ្មានរោគសញ្ញា។ សូមធ្វើតាមការណែនាំ សម្រាប់ការណែនាំការធ្វើចត្តាឡីស័កនៅផ្ទះ សម្រាប់ជំងឺ COVID-19។

☐ ***ណែនាំអោយធ្វើ៖*** ក្រុមការងារអនុលោមតាមសាលារៀន នឹងកំណត់ថាតើចាំបាច់ត្រូវមានការជូនដំណឹងបន្ថែម ដើម្បីជូនដំណឹងដល់សហគមន៍សាលារៀន អោយបានទូលំទូលាយជាងមុន អំពីការប្រឈម/ប៉ះ ពាល់ និងការប្រុងប្រយ័ត្នរបស់សាលារៀន ដែលត្រូវបានធ្វើឡើង ដើម្បីការពារការរីករាលដាលនៃជំងឺ COVID-19។ គំរូលិខិតជូនដំណឹងទូទៅ មាននៅឯៈ គំរូលិខិតជូនដំណឹងសំរាប់គ្រឹះស្ថានអប់រំ អំពីជំងឺ COVID-19។

---

## ការគ្រប់គ្រងការប្រឈម/ប៉ះពាល់សំរាប់ជំងឺ COVID-19 ពីរករណី នៅសាលារៀន ក្នុងរយៈពេល ១៤ ថ្ងៃ

---

☐ **ចាំបាច់ធ្វើ៖** ប្រសិនបើសាលារៀនត្រូវបានជូនដំណឹងអំពីករណីដែលបានបញ្ជាក់ ចំនួន ២ ករណី (សិស្ស និង/ឬនិយោជិក) ក្នុងរយៈពេល ១៤ ថ្ងៃ, សាលារៀននឹងអនុវត្តតាមជំហ៊ានចាំបាច់នានា សម្រាប់ករណីដែលបានបញ្ជាក់ ១ ករណី។

☐ ***ណែនាំអោយធ្វើ៖*** ក្រុមការងារអនុលោមតាមសាលារៀន ប៉ាន់ប្រមាណ ថាតើករណីដែលបានបញ្ជាក់ចំនួន ២ ករណី មានទំនាក់ទំនងនឹងរោគរាតត្បាត (ឧទាហរណ៍, មានវត្តមាននៅកន្លែង និងពេលវេលាតែមួយ ក្នុងកំឡុងពេលឆ្លង*)។

*ករណីមួយ ត្រូវបានគេចាត់ទុកថាឆ្លងពី ៤៨ ម៉ោង មុនពេលមានរោគសញ្ញានានា លេចចេញមកជាលើកដំបូង រហូតដល់ពេលដែលពួកគេ មិនត្រូវបានដាក់អោយនៅឯកោទៀតឡើយ (មានន័យថា, មិនគ្រុនក្តៅ យ៉ាងហោចណាស់រយៈពេល ២៤ ម៉ោង, ដោយមិនប្រើថ្នាំដែលបន្ថយគ្រុនក្តៅ **និង** ប្រព័ន្ធនានាបានប្រសើរឡើង **និង** យ៉ាងហោចណាស់ ១០ ថ្ងៃ បានកន្លងផុតទៅ ចាប់តាំងពីរោគសញ្ញានានា បានលេចចេញឡើងដំបូង)។ មនុស្សម្នាក់ដែលតេស្តជំងឺ COVID-19 ឃើញមានវិជ្ជមាន ប៉ុន្តែមិនមានរោគសញ្ញាណាអ្វីនោះទេ ត្រូវបានគេចាត់ទុកថាឆ្លងពី ៤៨ ម៉ោង មុនពេលការធ្វើតេស្តរបស់ពួកគេ ត្រូវបានធ្វើឡើងរហូតដល់ ១០ ថ្ងៃក្រោយ ពីការធ្វើតេស្តរបស់ពួកគេ។*

- ការកំណត់នូវទំនាក់ទំនង ឬតំណរភ្ជាប់នៃរោគរាតត្បាត រវាងករណីនានា អាចតម្រូវអោយមានការស៊ើបអង្កេតបន្ថែមទៀត ដើម្បីស្វែងយល់ពីប្រវត្តិនៃការប្រឈម/ប៉ះពាល់ និងកំណត់នូវទីតាំង និងមនុស្សទាំងអស់ ដែលអាចត្រូវបានប្រឈមនឹងករណីនេះ នៅខណៈពេលឆ្លង។ ឧបករណ៍មួយអាចរកបាន ដើម្បីជួយក្នុងការវាយតំលៃ នៃទំនាក់ទំនងរោគរាតត្បាត នៅឯ: សន្លឹកកិច្ចការស៊ើបអង្កេត ការប្រឈម/ប៉ះពាល់ជំងឺ COVID-19 សម្រាប់វិស័យអប់រំ។
- ប្រសិនបើមិនមានទំនាក់ទំនង ឬតំណរភ្ជាប់រោគរាតត្បាត ទេនោះ, សាលារៀនបន្តការត្រួតពិនិត្យការប្រឈម/ប៉ះពាល់ របស់ជំងឺ COVID-19 ជាប្រចាំ។
- ប្រសិនបើមានទំនាក់ទំនងរោគរាតត្បាត, សាលារៀនពង្រឹងសារដល់សិស្ស និងនិយោជិកទំងទូលាយ អំពីការប្រុងប្រយ័ត្ន ដើម្បីការពារការរីករាលដាល នៅឯសាលារៀន, រួមបញ្ចូលទាំងការអនុវត្តនូវបទអន្តរាគមន៍ នៅតាមកន្លែងជាក់លាក់នានា។

---

## ការគ្រប់គ្រងការប្រឈម/ប៉ះពាល់សំរាប់ជំងឺ COVID-19 ពីរច្រើនជាងបីករណី នៅសាលារៀន ក្នុងរយៈពេល ១៤ ថ្ងៃ

---

☐ **ចាំបាច់ធ្វើ៖** ប្រសិនបើសាលារៀន ត្រូវបានជូនដំណឹងអំពីបណ្តុំ/ចង្កោមនៃករណីចំនួន ៣ ករណីដែលបានបញ្ជាក់ ឬច្រើនជាងនេះ (សិស្ស និង/ឬ និយោជិក) ក្នុងរយៈពេល ១៤ ថ្ងៃ, សាលារៀនដំណើរការនូវជំហ៊ាននានា ដូចខាងក្រោម:

- ○ រាយការណ៍អំពីចង្កោមទៅកាន់កម្មវិធីត្រួតពិនិត្យជំងឺឆ្លង របស់នាយកដ្ឋានសុខាភិបាល ឡុងប៊ីឆ ក្នុងរយៈពេល ១ ថ្ងៃ នៃថ្ងៃធ្វើការ នៃការជូនដំណឹងអំពីចង្កោមនេះ ទៅលេខ ៥៦២.៥៧០.៤៣០២។
- ○ បំពេញបញ្ជីរាយខ្សែស្រឡាយសម្រាប់ករណី និងទំនាក់ទំនងទាំងឡាយ, រកបាន ឬ មានមាននៅ: ករណី COVID-19 និងបញ្ជីទំនាក់ទំនងខ្សែស្រឡាយ សម្រាប់វិស័យអប់រំ ហើយបញ្ជូនទៅកាន់ COVID19Edu@longbeach.gov។
- ○ ក្រុមជំងឺ COVID-19 សាលារៀន របស់នាយកដ្ឋានសុខាភិបាល និងពិនិត្យបញ្ជីខ្សែស្រឡាយករណី និងទំនាក់ទំនងទាំងឡាយ ដើម្បីកំណត់ថាតើ ការផ្ទុះឡើងត្រូវបាន បំពេញ/សមស្របតាមលក្ខណៈវិនិច្ឆ័យ ឬអត់។
- ○ ប្រសិនបើវាត្រូវបានគេកំណត់ថា លក្ខណៈវិនិច្ឆ័យនៃការផ្ទុះឡើង មិនត្រូវបានបំពេញ/សមស្របនោះទេ, បន្តការត្រួតពិនិត្យជាប្រចាំ អំពីការប្រឈម/ប៉ះពាល់នៃជំងឺ COVID-19។
- ○ ប្រសិនបើវាត្រូវបានកំណត់ថា លក្ខណៈវិនិច្ឆ័យនៃការផ្ទុះឡើង ត្រូវបានបំពេញ/សមស្រប, នាយកដ្ឋានសុខាភិបាល និងពិគ្រោះយោបល់ជាមួយសាលារៀន ស្តីអំពីការស៊ើបអង្កេត និងការគ្រប់គ្រងនូវការផ្ទុះឡើងនោះ។
- ○ ក្រុមការងារអនុលោមសាលារៀន និងបញ្ជូនព័ត៌មានដែលបានស្នើសុំ, រួមទាំងព័ត៌មានថ្មីៗ/ទាន់សម័យ បញ្ជីរាយខ្សែស្រឡាយអប់រំសម្រាប់ករណី និងទំនាក់ទំនងទាំងឡាយ ទៅកាន់អ្នកស៊ើបអង្កេត OMB រហូតដល់ការផ្ទុះឡើង ត្រូវបានដោះស្រាយ (យ៉ាងហោចណាស់ ១៤ ថ្ងៃ ចាប់តាំងពីករណីដែលបានបញ្ជាក់ចុងក្រោយ)។

☐ ***ណែនាំអោយធ្វើ៖*** មុនពេលរាយការណ៍អំពីចង្កោម, ក្រុមការងារអនុលោមសាលារៀន និងវាយតម្លៃថាតើមានយ៉ាងហោចណាស់ ៣ ករណី នៅក្នុងចង្កោមនេះ មានទំនាក់ទំនងឬតំណរភ្ជាប់នឹងរោគរាតត្បាត ដែរឬទេ។ ឧបករណ៍មួយអាចរកបាន ដើម្បីជួយក្នុងការវាយតំលៃ នៃទំនាក់ទំនងរោគរាតត្បាត នៅឯ: សន្លឹកកិច្ចការស៊ើបអង្កេត ការប្រឈម/ប៉ះពាល់ជំងឺ COVID-19 សម្រាប់វិស័យអប់រំ។

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 OR**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

**<u>បណ្តុំ/ចង្កោមសាលារៀន</u>**

យ៉ាងហោចណាស់ មានការបញ្ជាក់ពីមន្ទីរពិសោធន៍ ចំនួន ៣ ករណី ពីក្រុមគ្រួសារផ្សេងៗគ្នា ដែលបង្ហាញរោគសញ្ញានានា ឬមិនមានបង្ហាញនូវរោគសញ្ញានានា នៃជំងឺ COVID-19 ឡើយ ក្នុងរយៈពេល ១៤ ថ្ងៃ នៅក្នុងក្រុម (ច្រើន)* ដែលមានទំនាក់ទំនងនឹងរោគរាតត្បាត។

**ក្រុម (ច្រើន) រួមបញ្ចូលនូវមនុស្សនានា ដែលចែករំលែកសមាជិកភាពទូទៅ, ឧទាហរណ៍ ដូចជា ថ្នាក់រៀន, ព្រឹត្តិការណ៍សាលារៀន, សកម្មភាពមុខវិជ្ជាបន្ថែមសាលារៀន, ថ្នាក់សិក្សា, ក្រុមកីឡា, ក្លឹប, ការដឹកជញ្ជូន។*

**តារាង A: ជំហ៊ាននានា សំរាប់ការគ្រប់គ្រងការប្រឈម/ប៉ះពាល់ករណី ១, ២ និង ≥ ៣ នៃជំងឺ COVID-19 នៅសាលារៀន**

| | |
|---|---|
| **១ ករណី** | 1. សាលារៀនទទួលនូវការជូនដំណឹង អំពីករណីដែលបានបញ្ជាក់ចំនួន ១ ករណី នៅសាលារៀន។<br>2. *ចាំបាច់ធ្វើ៖* សាលារៀន ស្នើសុំថាករណីនោះ អនុវត្តតាមសេចក្តីណែនាំដាក់ខ្លួនអោយនៅឯកោ នៅផ្ទះសម្រាប់ ជំងឺ COVID-19 (a)។<br>3. *ចាំបាច់ធ្វើ៖* សាលារៀនធ្វើការជាមួយករណី ដើម្បីកំណត់ទំនាក់ទំនងដែលត្រូវបានប្រឈម/ប៉ះពាល់នឹងករណីនៅសាលារៀននៅ ក្នុង ពេលឆ្លង។<br>4. *ចាំបាច់ធ្វើ៖* សាលារៀនជូនដំណឹងដល់ទំនាក់ទំនងនៃការប្រឈម/ប៉ះពាល់នៅសាលារៀន។ ទំនាក់ទំនងត្រូវតែធ្វើចត្តាឡីស័កនៅផ្ទះជាបន្ទាន់ រយៈពេល ១៤ ថ្ងៃ បន្ទាប់ពីមានការប្រឈម/ប៉ះពាល់ លើកចុងក្រោយ (b)។<br>5. *ណែនាំអោយធ្វើ៖* សាលារៀនអាចធ្វើការជូនដំណឹងទូទៅ ដើម្បីជូនដំណឹងដល់សហគមន៍សាលារៀនកាន់តែទូលំទូលាយឡើង (អ្នកទទួល  បានត្រូវកំណត់ដោយសាលារៀន) នៃការប្រឈម/ប៉ះពាល់ និងការប្រុងប្រយ័ត្នដែលត្រូវបានធ្វើ ដើម្បីការពារការរីករាលដាល។<br>6. សំគាល់: គំរូលិខិតជូនដំណឹងអំពីការប្រឈម/ប៉ះពាល់ និងការជូនដំណឹងទូទៅ មាននៅឯ: <u>គំរូលិខិតជូនដំណឹងសំរាប់គ្រឹះស្ថានអប់រំ អំពីជំងឺ COVID-19</u>។ |

LONGBEACH HEALTH & HUMAN SERVICES

<table>
<tr><td>២ ករណី</td><td>1. ចាំបាច់ធ្វើ៖ អនុវត្តតាមជំហ៊ាននានា សម្រាប់ ១ ករណី ដែលបានបញ្ជាក់។<br>2. ណែនាំអោយធ្វើ៖ ប្រសិនបើមានករណីកើតឡើងក្នុងរយៈពេល ១៤ ថ្ងៃ ពីគ្នា, សាលារៀននឹងកំណត់ថា តើមានទំនាក់ទំនង ឬតំណរភ្ជាប់រោគរាតត្បាត (epi) ដែរឬទេ (ករណីមានបង្ហាញនៅក្នុងកន្លែងតែមួយ ក្នុងកំឡុងពេលតែមួយខណៈពេលឆ្លង)។ ឧបករណ៍មួយអាចរកបាន ដើម្បីជួយក្នុងការវាយតំលៃ នៃទំនាក់ទំនងរោគរាតត្បាត នៅឯ: សន្លឹកកិច្ចការស៊ើបអង្កេត ការប្រឈម/ប៉ះពាល់ជំងឺ COVID-19 សម្រាប់វិស័យអប់រំ។<br>*<u>មិនមាន</u>ទំនាក់ទំនង Epi → បន្តការត្រួតពិនិត្យ នូវការប្រឈម/ប៉ះពាល់ជាប្រចាំ។<br>*<u>មាន</u>ទំនាក់ទំនង Epi → សាលារៀនពង្រឹងសារដល់សិស្ស និងនិយោជិកទាំងឡាយ អំពីការប្រុងប្រយ័ត្ន ដើម្បីការពារការរីករាលដាល; អនុវត្តនូវបទអន្តរាគមន៍ នៅតាមកន្លែងជាក់លាក់នានា, ទៅតាមតំរូវការ, ដើម្បីកាត់បន្ថយការឆ្លង។</td></tr>
<tr><td>ករណី ៣+</td><td>1. ចាំបាច់ធ្វើ៖ ប្រសិនបើមានចង្កោមនៃករណីចំនួនបី ឬច្រើនករណីបានកើតឡើង ក្នុងរយៈពេល ១៤ ថ្ងៃពីគ្នា, សាលារៀនជូនដំណឹង កម្មវិធីត្រួតពិនិត្យ<u>ជំងឺឆ្លង</u> តាមលេខ ៥៦២.៥៧០.៤៣០២។<br>2. ណែនាំអោយធ្វើ៖ មុនពេលជូនដំណឹងដល់នាយកដ្ឋានសុខភាពនៃចង្កោមករណី, សាលារៀនប៉ាន់ប្រមាណថាតើ មាននូវទំនាក់ទំនង epi សម្រាប់ ≥ ៣ ករណី។<br>3. ចាំបាច់ធ្វើ៖ បំពេញឯកសារ បញ្ជីរាយខ្សែស្រឡាយករណីជំងឺ COVID-19 និងទំនាក់ទំនងសម្រាប់វិស័យអប់រំ ដើម្បីកំណត់ថាតើ លក្ខណៈវិនិច្ឆ័យនៃការផ្ទុះឡើងត្រូវបានបំពេញ/សមស្រប។<br>*លក្ខណៈវិនិច្ឆ័យនៃការផ្ទុះឡើង <u>មិនត្រូវបានបំពេញ/សមស្រប</u> → សាលារៀនបន្តការត្រួតពិនិត្យការប្រឈម/ប៉ះពាល់ជាប្រចាំ។<br>*លក្ខណៈវិនិច្ឆ័យនៃការផ្ទុះឡើង <u>បានបំពេញ/សមស្រប</u> → កម្មវិធីគ្រប់គ្រងជំងឺឆ្លង និងជួយក្នុងការគ្រប់គ្រងការផ្ទុះឡើង<br>4. ចាំបាច់ធ្វើ៖ ក្នុងអំឡុងពេលនៃការស៊ើបអង្កេតនៃការផ្ទុះឡើង, សាលារៀនផ្តល់នូវព័ត៌មានថ្មីៗ/ទាន់សម័យជាទៀងទាត់ ដល់នាយកដ្ឋានសុខាភិបាល រហូតដល់ការផ្ទុះឡើងត្រូវបានដោះស្រាយ (យ៉ាងហោចណាស់ ១៤ ថ្ងៃ ចាប់តាំងពីករណីដែលបានបញ្ជាក់ចុងក្រោយ)។</td></tr>
<tr><td>(a)</td><td>បទបញ្ជារបស់មន្ត្រីសុខាភិបាល, ករណីត្រូវបានគេកំណត់អោយដាក់ខ្លួនឯងអោយនៅឯកោ រហូតដល់គ្មានជំងឺគ្រុនក្តៅ រយៈពេលយ៉ាងហោចណាស់ ២៤ ម៉ោង (ដោយមិនប្រើថ្នាំដែលបន្ថយអាការៈគ្រុនក្តៅ) ហើយ រោគសញ្ញានានាបានប្រសើរឡើង ហើយ យ៉ាងហោចណាស់ ១០ ថ្ងៃ បានកន្លងផុតទៅ ចាប់តាំងពីរោគសញ្ញានានា បានលេចចេញមកជាលើកដំបូង ឬ, ប្រសិនបើក្នុងករណីមិនមានរោគសញ្ញាអ្វីនោះទេ, រហូតដល់ ១០ ថ្ងៃបានកន្លងផុតទៅ បន្ទាប់ពី</td></tr>
</table>

| | |
|---|---|
| | ការធ្វើតេស្តឃើញវិជ្ជមាន របស់ពួកគេ។ http://longbeach.gov/globalassets/health/media-library/documents/diseases-and-condition/information-on/novel-coronavirus/health-orders/isolation-health-order |
| (b) | បទបញ្ជារបស់មន្ត្រីសុខាភិបាល, ទំនាក់ទំនងត្រូវបានកំណត់អោយធ្វើចត្តាឡីស័ក រយៈពេល ១៤ ថ្ងៃ ចាប់តាំងពីថ្ងៃនៃការប្រឈម/ប៉ះពាល់ចុងក្រោយ នៅខណៈពេលឆ្លង។ http://longbeach.gov/globalassets/health/media-library/documents/diseases-and-condition/information-on/novel-coronavirus/health-orders/quarantine-order |

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 OR**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**